# មេរៀនទី៥៧៖ អ្នកប្រាជ្ញស្វែងរកព្រះយេស៊ូវ

## ម៉ាថាយ ២៖១-១២

**មេរៀនសម្រាប់គ្រូ** (*យូធូបលីង*)៖ https://youtu.be/yiVpwjqo-pg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/lIGq2xne4sI

**គោលបំណង៖** ព្រះយេស៊ូវសាកសមទទួលបានការថ្វាយបង្គំពីយើង

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៥០៖៦** *“ឲ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ”។*

**ចំរៀង** (*យូធូបលីង*)៖

១. ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M

២. ហោរាបីទិសខាងកើត https://youtu.be/UFeP7HQQHMo

៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ៣. ល្បែងកំសាន្ត «ផ្លុំភ្លើងទៀន»

សម្ភារៈដែលត្រូវការ៖ ទៀនចំនួន១៥ដើម



១.យើងបែងចែកកុមារជា៣ក្រុម

២. តំរៀបទៀនជា៣ជួរក្នុង១ជួរ៥ដើមបន្ទាប់យើងដុតទៀននោះ

៣. ក្រុមនីមួយត្រូវឲ្យតំណាងក្រុមមកផ្លុំទៀនតំណាលគ្នា

៤. ហើយកុមារត្រូវផ្លុំតែ១ដង ឲ្យរលត់ទាំង៥ដើម ក្រុមណាផ្លុំបានរលត់ទាំងអស់ ក្រុមនោះជាអ្នកឈ្នះ យើងបន្តលេងល្បែងនេះរហូតដល់កុមារទាំងអស់នៅក្នុងក្រុម បានលេងរួចគ្រប់ៗគ្នា។

៥. បន្ទាប់ពីលេងល្បែងចប់ សូមពន្យល់កុមារថា ព្រះយេស៊ូវគឺជាពន្លឺ ដែលបានចូលមកក្នុងពិភពងងឹតនេះ ដើម្បីសង្គ្រោះមនុស្សគ្រប់រូប។

### ៤. ការណែនាំមេរៀន

កំណើតរបស់ព្រះយេស៊ូវគួរតែជាដំណឹងល្អដ៏ធំមួយសម្រាប់ពិភពលោកទាំងមូល។ ប៉ុន្តែមានមនុស្សមិនច្រើនទេដែលបានដឹងថាព្រះអង្គសង្គ្រោះបានប្រសូតមក។ កំណើតរបស់ទ្រង់ត្រូវអបអរសាទរយ៉ាង ស្ងប់ស្ងាត់ក្នុងស្នូកសត្វជាកន្លែងដែលសត្វស៊ីចំនី និងដេក។ ប៉ុន្តែមានអ្នកដែលមកពីឆ្ងាយបានដឹងថា ព្រះអង្គសង្គ្រោះជាស្តេចបានប្រសូតមកហើយ។ ពួកគេជាអ្នកប្រាជ្ញមកពីទិសខាងកើត។ តោះសូមឲ្យយើងរៀនអំពីអ្នកប្រាជ្ញ ដែលបានមកថ្វាយបង្គំព្រះយេស៊ូវជាព្រះសង្គ្រោះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលដែលព្រះយេស៊ូវយាងមក មានមនុស្សពិសេសបានមកសួរសុខទុក្ខទ្រង់។ ពួកគេជាអ្នកប្រាជ្ញមកពីទិសខាងកើត។ អ្នកប្រាជ្ញមកពីទិសខាងកើតបានសិក្សាពីផ្កាយទាំងនោះ។ ថ្ងៃមួយពួកគេបានឃើញផ្កាយ ដ៏ពិសេសមួយបង្ហាញខ្លួននៅលើផ្ទៃមេឃ។ ពួកគេបានដឹងថាផ្កាយនេះជាសញ្ញាបង្ហាញថា ព្រះអង្គសង្គ្រោះ នៃពិភពលោកបានប្រសូត្រមកហើយ! ដូច្នេះ ពួកគេបានដើរតាមផ្កាយនោះក្នុងដំណើរដ៏វែងឆ្ងាយ ហើយ បានមកដល់ក្រុងយេរូសាឡិម។

នៅពេលដែលពួកគេបានទៅសួរសុខទុក្ខស្តេចហេរ៉ូឌ (ស្តេចនៃប្រទេសអ៊ីស្រាអែលនៅពេលនោះ) ដើម្បីសួរថាតើស្តេចថ្មីបានប្រសូតនៅទីណា ស្តេចហេរ៉ូឌមានព្រះទ័យព្រួយជាខ្លាំង ពីព្រោះគាត់គិតថា មានអ្នកណាម្នាក់នឹងមកជំនួសគាត់។ ដូច្នេះហើយ គាត់ប្រាប់អ្នកប្រាជ្ញឲ្យប្រាប់គាត់ឲ្យដឹងផង ពេលដែលពួកគេរកឃើញស្តេចថ្មីនោះ ព្រោះគាត់ចង់ថ្វាយបង្គំព្រះអង្គដែរ។ ប៉ុន្តែស្តេចហេរ៉ូឌមានគម្រោងធ្វើគុតស្តេច ដែលទើបនឹងប្រសូតនោះ។ តាមរយៈការដើរតាមផ្កាយ អ្នកប្រាជ្ញបានរកឃើញព្រះយេស៊ូវ ដែលជាស្តេច និងជាព្រះអង្គសង្គ្រោះនៃពិភពលោកនេះ។ កិច្ចការដំបូងដែលពួកគេបានធ្វើគឺថ្វាយបង្គំព្រះយេស៊ូវ ហើយថ្វាយអំណោយ របស់គេដល់ព្រះយេស៊ូវ។ បន្ទាប់មកគេនឹងត្រឡប់ទៅរកស្តេចហេរ៉ូឌវិញ ដើម្បីប្រាប់ថាស្តេចថ្មីនៅឯណា ប៉ុន្តែពួកគេត្រូវបានព្រះទ្រង់ពន្យល់ក្នុងសុបិនថា មិនឲ្យវិលទៅជួបស្តេចហេរ៉ូឌវិញទេ ដូច្នេះគេបានត្រឡប់ទៅស្រុកខ្លួនវិញតាមផ្លូវផ្សេងវិញ។

ព្រះយេស៊ូវសាកសមនឹងទទួលការគោរពនឹងថ្វាយបង្គំ។ ទ្រង់ជាព្រះអង្គសង្គ្រោះ និងជាស្តេចរបស់យើង។ តើអ្នកថ្វាយបង្គំព្រះយេស៊ូវដោយរបៀបណា? មនុស្សខ្លះគិតថាយើងគោរពថ្វាយបង្គំព្រះយេស៊ូវបានតែក្នុងព្រះវិហារតែប៉ុណ្ណោះ។ វាមិនពិតនោះទេ។ យើងត្រូវថ្វាយបង្គំទ្រង់អស់ពីចិត្តជារៀងរាល់ថ្ងៃ មិនថាយើងនៅទីណាក៏ដោយ! យើងថ្វាយបង្គំព្រះយេស៊ូវ ដោយយើងស្រឡាញ់ព្រះ និងស្រឡាញ់មនុស្ស!

## ៦. សំនួរពិភាក្សា

១. តើអ្នកប្រាជ្ញមកពីណា? *(ពីទិសខាងកើត)*

២.តើពួកហោរាបានមករកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះដែលប្រសូតមកជាមនុស្សតាមរយៈអ្វី? *(ពួកគេបានមកតាមរយៈផ្កាយពិសេសមួយនាំផ្លូវ)*

៣. តើពួកគេទៅជួបនរណាមុនគេ ពេលដែលពួកគេដើរស្វែងរកស្តេចថ្មី? *(ស្តេចហេរ៉ូឌ)*

៤. តើការពីរយ៉ាងអ្វីខ្លះដែលអ្នកប្រាជ្ញបានធ្វើនៅពេលពួកគេបានរកឃើញព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ? *(ពួកគេបានថ្វាយបង្គំទ្រង់ ហើយថ្វាយអំណោយដល់ទ្រង់)*

៥. តើយើងថ្វាយបង្គំព្រះយេស៊ូវយ៉ាងដូចម្តេច? *(ជារៀងរាល់ថ្ងៃ ដោយស្រឡាញ់ព្រះ និងស្រឡាញ់មនុស្ស)*

## ៧. ល្បែងកំសាន្ត «ស្វែងរកផ្កាយ»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង(សម្រាប់កុមារគ្រប់គ្នា) ក្រដាសដែលមានសរសេរអក្សរនៅក្នុងនោះ(ផ្កា ព្រះអាទិត្យ ព្រះចន្ទ ផ្លែឈើ ។ល។) ហើយក្រដាសមួយសរសេរពាក្យថា "ផ្កាយ"



១.សូមឲ្យប៉េងប៉ោងទៅកុមារគ្រប់គ្នាម្នាក់មួយៗ ដែលបានសរសេររួចជាស្រេច



២.កុមារទាំងអស់ត្រូវព្យាយាមផ្លុំប៉េងប៉ោងនោះរហូតទល់តែ ប៉េងប៉ោងនោះបែក។

៣. អ្នកណាដែលទទួលបានប៉េងប៉ោងមាន "រូបផ្កាយ" អ្នកនោះគឺជា អ្នកឈ្នះ។

៤. បន្ទាប់ពីការលេងល្បែងចប់ សូមពន្យល់កុមារថា ដូចជាផ្កាយមួយបានដឹកនាំអ្នកប្រាជ្ញអីចឹង គឺមានតែព្រះយេស៊ូវមួយប៉ុណ្ណោះ ដែលដឹកនាំជីវិត របស់យើង។ ដូច្នេះ យើងគួរតែថ្វាយបង្គំតែព្រះយេស៊ូវតែមួយអង្គប៉ុណ្ណោះ។



## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ១៥០៖៦** *"ឲ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ"។*

## ៩. ហាត្ថកម្ម «តោះបង្កើតផ្កាយ!»

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសដែលមានរូបផ្កាយឲ្យកុមារគ្រប់គ្នា ខ្សែ កន្ត្រៃ ខ្មៅដៃពណ៌ និងជ័រ




១.ឲ្យក្រដាសរូបផ្កាយ ដែលបានបោះពុម្ពរូបទៅកុមារគ្រប់គ្នា ហើយឲ្យពួកគេកាត់រូបផ្កាយម្នាក់២ៗ ចេញមកដោយយកចិត្តទុកដាក់។

២. សូមឲ្យកុមារធ្វើការតុបតែងផ្កាយនោះ

៣.សូមបត់ក្រដាសតាមគំនូសបន្ទាត់ដើម្បីបង្កើតបានជាផ្កាយ 3D *(រូបផុស)*

៤.សូមបិតផ្កាយទាំង២ផ្នែកបញ្ចូល គ្នា។

៥.អ្នកក៏អាចបិតខ្សែភ្ជាប់ជាមួយផ្កាយបានដែរ ដើម្បីឲ្យអ្នកអាចព្យួរវាបាន។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
អ្នកប្រាជ្ញទាំងបីបានធ្វើដំណើរជាយូរមកហើយដើម្បីស្វែងរកព្រះយេស៊ូវ។ ពួកគេមិនមានម៉ូតូ ឬរថយន្តជិះនោះទេ។ ពួកគេត្រូវជិះលើលើសត្វអូដ្ឋធ្វើដំណើរកាត់វាលខ្សាច់។ វាពិបាកខ្លាំងណាស់សម្រាប់ពួកគេ តែពួកគេក៏មិនចុះចាញ់ ពីព្រោះពួកគេពិតជាចង់ជួបស្តេចសង្គ្រោះ គឺព្រះយេស៊ូវ។ សម្រាប់យើង ហើយយើងមិនចាំបាច់ធ្វើដំណើរដ៏ឆ្ងាយដើម្បីស្វែងរកព្រះយេស៊ូវទេ។ ព្រះយេស៊ូវគឺគង់នៅជាមួយយើងជាស្រេចហើយ! សូមឲ្យយើងដឹងគុណព្រះដែលធ្វើឲ្យយើងកាន់តែងាយស្រួលក្នុងការបម្រើ និងថ្វាយបង្គំព្រះយេស៊ូវ។

# ហត្ថកម្ម «តោះបង្កើតផ្កាយ»



